# សំណង់អគារបៃតង និងការអភិវឌ្ឍសហគមន៍ ដោយចីរភាព


អ្នកដឹកនាំគម្រោង៖ Universität Hamburg – DER FORSCHUNG | DER LEHRE | DER BILDUNG

ឧបត្ថមដោយ៖ Federal Ministry of Education and Research


**ការរៀបចំគម្រោងប្រកបដោយចីរភាព និង គ្រប់ជ្រុងជ្រោយ បានបង្ហាញនូវការរចនាអគារបៃតង-ខៀវ ដែលឈានមុខគេ ដោយរាប់បញ្ចូលការសន្សំសំចៃ ធនធាន និង ទស្សនៈ ប្រើប្រាស់ថាមពលមានប្រសិទ្ធភាព សម្រាប់ការអភិវឌ្ឍលំនៅដ្ឋានរួមគ្នា នៅទីក្រុងកំពង់ផែ (Hafencity) Hamburg។**



រូបភាពបែរទៅរកផ្លូវ (រូបភាពទី១)

# We-House Baakenhafen Hamburg, ប្រទេសអាឡឺម៉ង់

## សាវតា និង ទិដ្ឋភាពទូទៅ

នៅក្នុងទីក្រុងកំពង់ផែ (Hafencity) នៃទីក្រុង Hamburg ការផ្តួចផ្តើមអគារដែលប្រកបដោយចីរភាព និងជាគំរូល្អនោះ នឹងត្រូវបានក្លាយជាការពិត។ ដោយផ្អែកលើគម្រោង ដ៏ជោគជ័យ របស់ក្រុមហ៊ុន Eble Messerschmidt Partner នៅក្នុងការប្រកួតប្រជែងដ៏មានឈ្មោះបោះសំឡេងនោះ ការរៀបចំប្លង់លំនៅដ្ឋានដែលឈានមុខគេ នឹងជំរុញអោយមានលទ្ធផលលំនៅដ្ឋានចីរភាពដ៏ខ្ពស់បំផុតមួយ។

គំនិតនៃការរៀបចំលំនៅដ្ឋានលក្ខណៈសមូហភាពនេះបានរួមបញ្ចូលនូវ លំនៅដ្ឋានផ្សេងៗគ្នា ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត មាន ភោជនីយដ្ឋាន និង លំហការិយាល័យដែលអាចធ្វើការរួមគ្នាបាន។



ប្រព័ន្ធការសាងសង់ដោយឈើបែបកូនកាត់ (រូបភាពទី២)

## គោលការណ៍ក្នុងការរចនា

### ការផ្គត់ផ្គង់ថាមពលកកើតឡើងវិញ

អគារនឹងត្រូវរៀបចំប្រកបដោយការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព ដោយរាប់បញ្ចូលទ្រនាប់ការពារជញ្ជាំងខាងក្រៅដ៏ល្អ ព្រមទាំង បង្អួច និង ដំបូល និង ប្រព័ន្ធខ្យល់ដែលអាចយកកម្តៅមកប្រើប្រាស់ឡើងវិញ។ ជាងនេះទៅទៀតរាល់អគារបែបនេះ នឹងត្រូវភ្ជាប់ជាមួយប្រព័ន្ធបណ្តាញកម្តៅខាងក្នុងផ្ទះ របស់ក្រុង Hafencity ទៀតផង។ អគារនេះ នឹងត្រូវផ្តល់បន្ថែមនូវ ផ្ទាំងPV ជាច្រើននៅផ្នែក Façade និងលើដំបូល។

### លំហូរចូលវត្ថុធាតុដើមប្រកបដោយចីរភាព

ការរៀបចំ ផ្គត់ផ្គង់សម្ភារៈប្រកបដោយចីរភាព ប្រព័ន្ធរៀបចំផ្គត់ផ្គង់សម្ភារៈទាន់សម័យ ដោយមានអគារសមាហរណកម្មជីវម៉ាស និងការគ្រប់គ្រងប្រព័ន្ធទឹកមានវិភាគទានដ៏សំខាន់ ដល់សេដ្ឋកិច្ចជាប្រព័ន្ធ។ ទឹកសំអុយនឹងត្រូវធ្វើប្រព្រឹត្តកម្មជាមួយប្រព័ន្ធចម្រោះលើតំបូលហើយត្រូវប្រើសម្រាប់ស្រោចស្រពនិងបន្ទប់ទឹក។ ជីវម៉ាសត្រូវបានគេប្រើសម្រាប់ លាយដីដ៏មានជីវជាតិ សម្រាប់ការដាំដុះ នៅក្នុងគេហដ្ឋាន ដែលហៅថា Terra Preta។

### ការសាងសង់ប្រកបដោយចីរភាព

សម្ភារៈ និង ប្រព័ន្ធនៃការសាងសង់ទាំងអស់ត្រូវបានរៀបចំឡើងសម្រាប់សន្សំសំចៃធនធានថាមពលដែលត្រូវយកមកប្រើតិចបំផុត (ឬក៏អាចជាការចាប់យកកាបូន) និងបរិស្ថានក្នុងផ្ទះប្រកបដោយផាសុខភាព។ អគារកម្ពស់៨ជាន់នោះ ភ្ជាប់ប្រព័ន្ធសាងសង់ពីឈើដែលមានលក្ខណៈកូនកាត់ដ៏ធំសម្បើម រួមមានជញ្ជាំងឈើខាងក្រៅ និងស្រោបដោយឈើកាបូណាយ (Carbonised)។

### ជីវសាស្ត្រចម្រុះ និង ផាសុខភាពក្នុងទីក្រុង

ទស្សនៈ អគារ បៃតង ខៀវ បានជំរុញឲ្យមានកំណើនជីវសាស្ត្រចំរុះ ផាសុខភាព និងសួនច្បារក្នុងទីក្រុង។ ភាគច្រើនផ្នែកមុខអគារមានកំណើន Façade បៃតង។ ច្បារខាងលើដំបូលអាចផលិតបន្លែ ផ្លែឈើ ដែលអាចផ្គត់ផ្គង់ ដល់ភោជនីយដ្ឋាននៅជាន់ក្រោម។



រូបមើលពីសួន Baakenhafen (រូបភាពទី៣)




ប្លង់ដំបូល (រូបភាពទី៤)



យុទ្ធសាស្ត្រថាមពល (រូបភាពទី៥)



យុទ្ធសាស្ត្របៃតង (រូបភាពទី៦)



យុទ្ធសាស្ត្រទឹក (រូបភាពទី៧)

| | |
|---|---|
| ទីតាំង: | Hamburg Hafencity, Germany |
| អ្នកសាងសង់: | Archy Nova Project Development with DeepGreen Development |
| ផ្ទៃដីសរុប: | Ca. 4.300 m² |
| ស្ថាបត្យករ: | Eble Messerschmidt Partner |
| ទីប្រឹក្សា: | Knippers Helbig, Ramboll Studio Dreiseitl, J. Böttcher, Forest Farmers, EE Concept, Knecht Engineers |
| ពានរង្វាន់: | 1st price in competition 2020 |


សូមថ្លែងអំណរគុណចំពោះ ៖
fig. 2, 4-7 Eble Messerschmidt Partner    fig. 1+3 Moka-Studio Hamburg